ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ៖

- **ផែនការរៀបចំដែនដីថ្នាក់ខេត្ត** ជាផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសនៃការប្រើប្រាស់ដីនិងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រនិងតំបន់នីមួយៗក្នុងក្របខ័ណ្ឌថ្នាក់ខេត្ត។
- **ប្លង់គោលប្រើប្រាស់ដីថ្នាក់រាជធានី ថ្នាក់ក្រុង ថ្នាក់ស្រុក ថ្នាក់ខណ្ឌ** ជាផែនការកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍផ្នែករូបវន្ត និងកំណត់អំពីប្រភេទដី ព្រមទាំងបង្ហាញអំពីបណ្តាញហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍សំខាន់ៗ និងការធ្វើសមាហរណកម្មក្របខ័ណ្ឌថ្នាក់រាជធានី ថ្នាក់ក្រុង ស្រុក ខណ្ឌ ទៅនឹងថ្នាក់តំបន់ និងថ្នាក់ជាតិ។
- **ផែនការប្រើប្រាស់ដីថ្នាក់រាជធានី ថ្នាក់ក្រុង** ជាផែនការលំអិតចេញពីប្លង់គោលដែលកំណត់អំពីប្រភេទនៃការប្រើប្រាស់ដីនៅតំបន់នីមួយៗកំណត់អំពីបទប្បញ្ញត្តិប្រើប្រាស់ដី ការអភិវឌ្ឍដី និងលទ្ធភាពនៃការសាងសង់ក្នុងតំបន់នីមួយៗ ព្រមទាំងបង្ហាញអំពីប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនិងការធ្វើសមាហរណកម្មទៅថ្នាក់តំបន់និងថ្នាក់ជាតិ។

## ជំពូកទី២
## សមាសភាព តួនាទី និងភារកិច្ចរបស់
## គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់រាជធានី ខេត្ត

**មាត្រា ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| - អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ០១រូប | អនុប្រធាន |
| - ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| - តំណាងក្រុមប្រឹក្សារាជធានី ខេត្ត ០១រូប | សមាជិក |
| - ប្រធានមន្ទីរនិងប្រធានអង្គភាពពាក់ព័ន្ធនានាជុំវិញរាជធានី ខេត្ត | សមាជិក |
| - នាយករដ្ឋបាល សាលារាជធានី ខេត្ត | សមាជិក |
| - អភិបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ | សមាជិក |

- តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត ០២រូប សមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
របស់ក្រុមប្រឹក្សារាជធានី ខេត្ត ០១រូប សមាជិក។

តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត ០២រូប ត្រូវចាត់តាំងឡើងដោយគណៈកម្មាធិការប្រតិបត្តិនៃសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត។ តំណាងទាំងពីររូបនេះត្រូវមានស្ត្រីយ៉ាងតិចមួយរូប។

ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត មានលេខាធិការដ្ឋានមួយជាសេនាធិការ ដឹកនាំដោយអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងមានសមាសភាពមកពីសាលារាជធានី ខេត្ត និងតំណាងមន្ទីរ និងអង្គភាពពាក់ព័ន្ធជុំវិញរាជធានី ខេត្ត ជាសមាជិក។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម រាជធានី ខេត្ត ត្រូវស្នើសុំការសម្រេចពីក្រុមប្រឹក្សារាជធានី ខេត្ត អំពីសមាសភាពនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននេះ។

## ផ្នែកទី១ : ថ្នាក់រាជធានី

### មាត្រា ៤.-

នៅថ្នាក់រាជធានី មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ត្រូវផ្តួចផ្តើមនិងរៀបចំឡើងដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី និងសម្របសម្រួលដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ(**គ.ជ.ន.ជ.**)។ ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ត្រូវសម្រេចដាក់ឲ្យប្រើប្រាស់ដោយអនុក្រឹត្យ។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនេះ ត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច២០(ម្ភៃ)ឆ្នាំខាងមុខ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

នីតិវិធីលំអិតស្តីពីការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ន.ជ.**។

### មាត្រា ៥.-

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ផ្តួចផ្តើមនិងរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ និងផែនការប្រើប្រាស់ដីថ្នាក់សង្កាត់ ឲ្យមានប្រសិទ្ធភាព និងចំទិសដៅ
- ដឹកនាំពិគ្រោះយោបល់ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន ក្រុមប្រឹក្សា និងអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី

- ពិនិត្យនិងផ្តល់យោបល់ជូនក្រុមប្រឹក្សារាជធានី លើប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី លើប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ និងផែនការប្រើប្រាស់ដីថ្នាក់សង្កាត់
- ស្នើសុំការយល់ព្រមពី **គ.ជ.ន.ជ.** ចំពោះប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- ស្នើសុំការសម្រេចពី **គ.ជ.ន.ជ.** លើប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ
- កែសម្រួលនិងធ្វើបច្ចុប្បន្នកម្ម លើប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ទៅតាមរយៈពេលកំណត់
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំជូន **គ.ជ.ន.ជ.** អំពីលទ្ធផលនៃការអនុវត្តការងារ
- លើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- បំពេញភារកិច្ចដែលពាក់ព័ន្ធនឹងការងាររៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ន.ជ.** ប្រគល់ជូន។

## ផ្នែកទី២ : ថ្នាក់ខេត្ត

**មាត្រា ៦.-**

នៅថ្នាក់ខេត្តមានផែនការរៀបចំដែនដីថ្នាក់ខេត្ត។

ផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវផ្តួចផ្តើមនិងរៀបចំឡើងដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត ដោយមានការឯកភាពពីក្រុមប្រឹក្សាខេត្ត។ ផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវសុំការយល់ព្រមពី **គ.ជ.ន.ជ.** និងសម្រេចដាក់ឲ្យប្រើប្រាស់ដោយអនុក្រឹត្យ។

ផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច២០(ម្ភៃ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

នីតិវិធីលំអិតស្តីពីការរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្តត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ន.ជ.**។

**មាត្រា ៧.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្តមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ផ្តួចផ្តើមនិងរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្ត
- ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តផែនការរៀបចំដែនដីថ្នាក់ខេត្ត ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក និងផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ឲ្យមានប្រសិទ្ធភាពនិងចំទិសដៅ
- ដឹកនាំពិគ្រោះយោបល់ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការរៀបចំផែនការរៀបចំដែនដីថ្នាក់ខេត្ត
- ពិនិត្យនិងផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្តលើផែនការរៀបចំដែនដីថ្នាក់ខេត្ត លើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង លើប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក និងផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់

- ស្នើសុំការយល់ព្រមពី **គ.ជ.ន.ជ.**លើផែនការរៀបចំដែនដីថ្នាក់ខេត្ត
- ស្នើសុំការសម្រេចពី **គ.ជ.ន.ជ.**លើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងលើប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក
- ពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នកម្ម លើផែនការរៀបចំដែនដីថ្នាក់ខេត្តតាមរយៈពេលកំណត់
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូន **គ.ជ.ន.ជ.**អំពីលទ្ធផលនៃសកម្មភាពការងារ
- លើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ខេត្ត
- បំពេញភារកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងាររៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីក្នុងក្របខ័ណ្ឌថ្នាក់ខេត្ត
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល **គ.ជ.ន.ជ.** ប្រគល់ជូន។

## ជំពូកទី៣
## សមាសភាព តួនាទី និងភារកិច្ចរបស់
## គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ

**មាត្រា ៨.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | ប្រធាន |
| - អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ០១រូប | អនុប្រធាន |
| - ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ | សមាជិកអចិន្ត្រៃយ៍ |
| - តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ០១រូប | សមាជិក |
| - នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | សមាជិក |
| - ប្រធានការិយាល័យនិងប្រធានអង្គភាពពាក់ព័ន្ធក្នុងក្រុង ស្រុក ខណ្ឌ | សមាជិក |
| - មេឃុំ ចៅសង្កាត់ទាំងអស់ក្នុងក្រុង ស្រុក ខណ្ឌ | សមាជិក |
| - តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | សមាជិក |

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌមានក្រុមការងាររៀបចំដែនដីនិងនគរូបនីយកម្មមួយ ជាសេនាធិការ ដឹកនាំដោយអនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ និងមានសមាសភាពពីសាលាក្រុង ស្រុក ខណ្ឌ និងតំណាងការិយាល័យនិងអង្គភាពពាក់ព័ន្ធជុំវិញក្រុង ស្រុក ខណ្ឌ ជាសមាជិក។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវស្នើសុំការសម្រេចពីក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អំពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមការងារនេះ។

## ផ្នែកទី១ : ថ្នាក់ក្រុង

**មាត្រា ៩.-**

នៅថ្នាក់ក្រុង មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ត្រូវផ្តួចផ្តើមនិងរៀបចំដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់ក្រុង ដោយមានការឯកភាពពីក្រុមប្រឹក្សាក្រុង ពីក្រុមប្រឹក្សារាជធានី ខេត្ត តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងសម្រេចដាក់ឲ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ន.ជ.**។

ប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

នីតិវិធីលំអិតស្តីពីការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ន.ជ.**។

**មាត្រា ១០.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ផ្តួចផ្តើមនិងរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង
- ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងផែនការប្រើប្រាស់ដីថ្នាក់សង្កាត់ឲ្យមានប្រសិទ្ធភាពនិងចំទិសដៅ
- ដឹកនាំពិគ្រោះយោបល់ សម្របសម្រួលជាមួយការិយាល័យនិងអង្គភាពពាក់ព័ន្ធក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង
- ពិនិត្យនិងផ្តល់យោបល់ជូនក្រុមប្រឹក្សាក្រុងលើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង និងផែនការប្រើប្រាស់ដីថ្នាក់សង្កាត់
- កែសម្រួលនិងធ្វើបច្ចុប្បន្នកម្មលើប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុងតាមរយៈពេលកំណត់
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត អំពីលទ្ធផលនៃសកម្មភាពការងាររបស់ខ្លួន
- លើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង
- បំពេញភារកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងាររៀបចំកសាងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីក្នុងក្របខ័ណ្ឌថ្នាក់ក្រុង
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ប្រគល់ជូន។

## ផ្នែកទី២ : ថ្នាក់ស្រុក

**មាត្រា ១១.-**

នៅថ្នាក់ស្រុក មានប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក។

ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ត្រូវផ្តួចផ្តើមនិងរៀបចំដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ស្រុក ដោយមានការឯកភាពពីក្រុមប្រឹក្សាស្រុក។ ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ត្រូវមានការឯកភាពពីក្រុមប្រឹក្សាខេត្ត តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត និងសម្រេចដាក់ឲ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ន.ជ.**។

ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុកត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

នីតិវិធីលំអិតស្តីពីការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ន.ជ.**។

**មាត្រា ១២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ស្រុក មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ផ្តួចផ្តើមនិងរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក
- ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុកនិងផែនការប្រើប្រាស់ដីថ្នាក់ឃុំ ឲ្យមានប្រសិទ្ធភាពនិងចំទិសដៅ
- ដឹកនាំ ពិគ្រោះយោបល់ និងសម្របសម្រួលជាមួយការិយាល័យនិងអង្គភាពពាក់ព័ន្ធ ក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក
- ពិនិត្យនិងផ្តល់យោបល់ជូនក្រុមប្រឹក្សាស្រុកលើប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក និងផែនការប្រើប្រាស់ដីថ្នាក់ឃុំ
- កែសម្រួលនិងធ្វើបច្ចុប្បន្នកម្មលើប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុកតាមរយៈពេលកំណត់
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត អំពីលទ្ធផលនៃសកម្មភាពការងារ
- លើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ស្រុក
- បំពេញភារកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងាររៀបចំកសាងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីក្នុងក្របខ័ណ្ឌថ្នាក់ស្រុក
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ប្រគល់ជូន។

## ផ្នែកទី៣ : ថ្នាក់ខណ្ឌ

**មាត្រា ១៣.-**

នៅថ្នាក់ខណ្ឌ មានប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ។

ប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ ត្រូវផ្តួចផ្តើមនិងរៀបចំដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខណ្ឌ ដោយមានការឯកភាពពីក្រុមប្រឹក្សាខណ្ឌ។ ប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ ត្រូវមានការឯកភាពពីក្រុមប្រឹក្សារាជធានី តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី និងសម្រេចដាក់ឲ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ន.ជ.**។

ប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌត្រូវមានចក្ខុវិស័យសម្រាប់រយៈពេលយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំ និងអាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង។

នីតិវិធីលំអិតស្តីពីការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ខណ្ឌ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ ប្រធាន **គ.ជ.ន.ជ.**។

**មាត្រា ១៤.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខណ្ឌ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ផ្តួចផ្តើមនិងរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ
- តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌនិងផែនការប្រើប្រាស់ដីថ្នាក់សង្កាត់ឲ្យមានប្រសិទ្ធភាពនិងចំទិសដៅ
- ដឹកនាំពិគ្រោះយោបល់ សម្របសម្រួលជាមួយការិយាល័យ និងអង្គភាពពាក់ព័ន្ធក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ
- ពិនិត្យនិងផ្តល់យោបល់ជូនក្រុមប្រឹក្សាខណ្ឌ លើប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌនិងផែនការប្រើប្រាស់ដីសង្កាត់
- កែសម្រួលនិងធ្វើបច្ចុប្បន្នកម្មលើប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌតាមរយៈពេលកំណត់
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី អំពីលទ្ធផលនៃសកម្មភាពការងាររបស់ខ្លួន
- លើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ
- បំពេញភារកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការងាររៀបចំកសាងប្លង់គោលប្រើប្រាស់ដីក្នុងក្របខ័ណ្ឌ ថ្នាក់ខណ្ឌ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្តប្រគល់ជូន។

## ជំពូកទី៤
## អំពីការគាំទ្របច្ចេកទេសនិងថវិកា

**មាត្រា ១៥.-**

**គ.ជ.ន.ជ.** អាចចេញសេចក្តីណែនាំបន្ថែមអំពីការងារបច្ចេកទេសពាក់ព័ន្ធដល់ការអនុវត្តតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៦.-**

ថវិកាសម្រាប់ដំណើរការគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ស្ថិតក្នុងកញ្ចប់ថវិការបស់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រៀងៗខ្លួន។

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិដែលបានមកពីហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និងសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ខែ មិថុនា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទការល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ